# របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម

**កម្មវិធីរបស់ The Asian International Justice Initiative**

**ឆ្នាំទី១ លេខ ១០** **សប្តាហ៍ទី១០ (២៩ មិថុនា — ២ កក្កដា ឆ្នាំ២០០៩)**


## "សវនាការអង្គសេចក្តីលើករណីអតីតប្រធានមន្ទីរ ស-២១ កាំង ហ្គិចអាវ ហៅ ឌុច"



*រូបភាព : លោក **ជុំ ម៉ី*** *លោក **ប៊ូ ម៉េង*** *លោក **នង ចាន់ផល***

## ១. សេចក្តីសង្ខេប

*"អ្វីដែលខ្ញុំស្វែងរក គឺយុត្តិធម៌... ខ្ញុំសង្ឃឹមថា យុត្តិធម៌នឹងមានសម្រាប់មនុស្សគ្រប់រូប"*

ដំណើរការក្តីនាសប្តាហ៍នេះ ផ្តោតសំខាន់លើការស្តាប់សក្ខីកម្មសាក្សីបួនរូប ដែលអះអាងថា ជាអតីតអ្នកទោសនៅមន្ទីរ ស-២១ ។ ពួកគេអាចរស់រានមានជីវិតដោយសារតែជំនាញ និងស្នាដៃរបស់គេ រួមមាន លោក **វ៉ាន់ ណាត** លោក **ជុំ ម៉ី** និងលោក **ប៊ូ ម៉េង** ដែលផ្តល់សក្ខីកម្ម អំពីបទពិសោធន៍ដ៏ទារុណ កំឡុងពេលគ្រប់គ្រងដោយរបបខ្មែរក្រហម ។ ការរំលឹកឡើងនូវព្រឹត្តិការណ៍ខ្លោចផ្សា បានបង្ខំឱ្យសាក្សីមានអារម្មណ៍រំជួលចិត្ត និងប្រតិកម្មជាខ្លាំង ។ សាក្សីប្រាកដច្បាស់ថា ការសម្រេចចិត្តចូលរួមសវនាការ គឺដើម្បីយុត្តិធម៌ជូនមនុស្សជាទីស្រឡាញ់ និងប្រជាពលរដ្ឋខ្មែរដែលបាត់បង់ជីវិតក្នុងរបបនោះ ។

## ២. បញ្ហាច្បាប់ និងនីតិវិធី

### ក. សក្ខីកម្មសាក្សី

ដំណើរការក្តីនាសប្តាហ៍នេះ ផ្តោតសំខាន់ទៅលើសក្ខីកម្មអ្នករស់រានមានជីវិតនៅមន្ទីរស-២១ ។ លោក **វ៉ាន់ ណាត** លោក **ជុំ ម៉ី** និងលោក **ប៊ូ ម៉េង** បានគេចផុតពីការកាប់សំលាប់ ដោយសារអាជីពជំនាញពួកគេ ដែលអង្គការចាត់ទុកថា មានប្រយោជន៍ចំពោះរបបខ្មែរក្រហម ។ លោក **នង ចាន់ផល** ដែលអះអាងថា ជាអ្នកទោសកុមារនៅមន្ទីរ ស-២១ គឺរកឃើញដោយកងទ័ពវៀតណាម នៅពេលរំដោះទីក្រុងភ្នំពេញ ។ **ឌុច** ទទួលយកដោយឥតប្រកែកថា លោក **វ៉ាន់ ណាត** លោក **ជុំ ម៉ី** និង លោក **ប៊ូ ម៉េង** ពិតជាបានរងគ្រោះក្រោមកណ្តាប់ដៃបុគ្គលិកនៅមន្ទីរ ស-២១ មែន ប៉ុន្តែគាត់សំដែងនូវការមន្ទិលសង្ស័យចំពោះការអះអាងរបស់លោក **នង ចាន់ផល** ដែលថា គាត់ជាអ្នកទោសកុមារមកជាមួយម្តាយនៅមន្ទីរ ស-២១ ព្រោះគ្មានឯកសារណាបញ្ជាក់ថា

ម្ដាយគាត់ជាប់នៅមន្ទីរ ស-២១ ឡើយ ។

***ការចាប់ខ្លួន និងបញ្ជូនទៅមន្ទីរ ស-២១ :*** ការរៀបរាប់ពីប្រវត្តិដើមរបស់សាក្សីមានលក្ខណៈស្រដៀងគ្នា ចំពោះកាលៈទេសៈនៃការចាប់ខ្លួន ។ សាក្សីបានលាតត្រដាងថា ពួកគេត្រូវបានបញ្ឆោតទៅកន្លែងមួយ ហើយក៏ចាប់ខ្លួនតែម្ដង (លើកលែងករណីលោក **ចាន់ផល**) ។ *ឧទា :* លោក **វ៉ាន់ ណាត** ត្រូវបានគេបញ្ជាទៅខេត្តពោធិសាត់ជាមួយ កម្មាភិបាលថ្នាក់ឃុំ ដែលតាមការពិតគេនាំគាត់ទៅទីនោះ ដើម្បីឃុំខ្លួនតែប៉ុណ្ណោះ ។ លោក **វ៉ាន់ ណាត** ត្រូវបានឃុំខ្លួន និងសួរចម្លើយនៅវត្តកណ្ដាល ដែលជាការិយាល័យសន្តិសុខ ប្រតិបត្តិការក្រោមការគ្រប់គ្រងតំបន់ពាយ័ព្យ មុនពេលបញ្ជូនមកកាន់មន្ទីរ ស-២១ ។ លោក **ជុំ ម៉ី** និង លោក **ប៊ូ ម៉េង** ត្រូវបាន នាំមកមន្ទីរ ស-២១ ក្រោមរូបភាពនៃការចាត់តាំងការងារថ្មីពីអង្គការ ។ ស្រដៀងគ្នានេះដែរ ម្ដាយ និងប្អូនប្រុសលោក **នង ចាន់ផល** ត្រូវបានបញ្ជូនមកមន្ទីរ ស-២១ ដោយប្រាប់ថា មកនៅជួបជុំប្ដី ។ ជាទូទៅគ្មានសាក្សីណាម្នាក់បានដឹងនូវមូលហេតុពិតប្រាកដនៃការចាប់ខ្លួនឡើយ ។ ផ្អែកតាមសក្ខីកម្មសាក្សី ប្រាកដណាស់ថា របបខ្មែរក្រហមចាត់ទុកការសម្ងាត់ជារឿងសំខាន់ ដោយ អ្នកទោសទាំងអស់ត្រូវបានរុំមុខ នៅពេលនាំចូលមន្ទីរ ស-២១ ។

***របៀបបទទទួលយកអ្នកទោសនៅមន្ទីរ ស-២១ :*** សក្ខីកម្មអ្នករស់រានមានជីវិតភាគច្រើនស៊ីសង្វាក់គ្នាជាមួយភស្តុតាងរបស់ជនជាប់ចោទ ចំពោះរបៀបបទទទួលយកអ្នកទោសនៅមន្ទីរ ស-២១ ។ ជាទូទៅ អ្នកទោសត្រូវថតរូបនៅពេលទៅដល់មន្ទីរ ស-២១ បន្ទាប់មកពួកគេត្រូវនាំទៅបន្ទប់ឃុំឃាំងរួម តាមផ្នែកស្រី ឬប្រុស ។ ពួកគេត្រូវដោះចេញ ឬបោះបង់ចោលសំលៀកបំពាក់បដិវត្តន៍ ព្រោះជាតំរូវការរបស់អង្គការ ។

***ស្ថានភាពនៃការឃុំឃាំង :*** តាមការរៀបរាប់អំពីប្រវត្តិដើមនាសម័យនោះ លោក **វ៉ាន់ ណាត** លោក **ជុំ ម៉ី** និងលោក **ប៊ូ ម៉េង** បានផ្ដល់នូវទស្សនៈវិស័យពីស្ថានភាពសាហាវយង់ឃ្នងនៅមន្ទីរឃុំឃាំង ស-២១ ។ ផ្អែកតាមសក្ខីកម្ម **ឌុច** និងសាក្សីបានឱ្យដឹងថា សកម្មភាពប្រព្រឹត្តមកលើពួកគេ គឺ *"ដូចសត្វធាតុ"* ដែលបានបំពានដោយកងសន្តិសុខផ្ទាល់ ។ ពួកគេបានបញ្ជាក់ថា អ្នកទោសទាំងអស់ក្នុងបន្ទប់ឃុំឃាំងរួម ត្រូវបានដាក់ខ្នោះជើងជាប់ជាមួយរនោងដែកវែង ហើយតឹងរឹងមិនឱ្យកំរើកខ្លួន ។ តាមរយៈសក្ខីកម្មសាក្សី ប្រាកដណាស់ថា មិនមានកន្លែងសម្រាប់ងូតទឹកនោះទេ ហើយអ្នកទោសជាប់ខ្នោះនៅពេលងូតទឹក ។ សាក្សីបានពន្យល់ថា ការងូតទឹក គឺកងសន្តិសុខគុកបាញ់ទឹកចូលក្នុងបន្ទប់ឃុំឃាំង ។ បន្ថែមពីលើនោះ ពួកគេមិនបានអនុញ្ញាតឱ្យចាកចេញពីបន្ទប់ឃុំឃាំង ដើម្បីបត់ដៃ បត់ជើងឡើយ ដោយបង្ខំឱ្យនោមដាក់ពីដុងទឹក និងបន្ទោរបង់ដាក់កេះគ្រាប់ ។ សាក្សីបានឱ្យដឹងថា អ្នកទោសបានទទួលរបបអាហារតិចតួច គឺបបរពាស្លាបព្រាតូចប៉ុណ្ណោះ ២ដងក្នុង១ថ្ងៃ ។ លោក **វ៉ាន់ ណាត** បានរំលឹកឡើងវិញនូវបទពិសោធន៍ពីការអត់ឃ្លាន *"បើទោះជាស៊ីសាច់មនុស្សជាអាហារក៏ហូបដែរ"* ។ តាមរយៈសក្ខីកម្មលោក **ជុំ ម៉ី** បញ្ជាក់បន្ថែមពីការស្ថានភាពឃុំឃាំង នៅក្នុងបន្ទប់ឃុំដាច់ដោយឡែក ដែលបន្ទប់នីមួយៗមានសណ្ឋានតូចចង្អៀត និងងងឹតសូនសូន្យ ។ អ្នកទោសត្រូវបានដាក់ច្រវ៉ាក់ ហើយបង្ខំឱ្យដេក និងហូបក្បែរកេះគ្រាប់លាមក ។ ផ្ទុយទៅវិញ របបអាហារ និងកន្លែងស្នាក់នៅរបស់សាក្សីមានលក្ខណៈល្អប្រសើរ កំឡុងពេលពួកគេបានទទួលការចាត់តាំងការងារថ្មី ។

***បច្ចេកទេសនៃការសួរចម្លើយ និងទារុណកម្ម :*** លោក **វ៉ាន់ ណាត** លោក **ជុំ ម៉ី** និងលោក **ប៊ូ ម៉េង** ត្រូវបានចោទប្រកាន់ថា ជាជនប្រឆាំងបដិវត្ត ដូចជាចោទ *"CIA ឬ KGB ដែលជាសត្រូវរបស់បក្ស"* ។ សាក្សីទាំង ៣រូបនេះ បានអះអាងថា ជាការចោទប្រកាន់ ដែលពួកគេមិនបានដឹងទាល់តែសោះអំពី *"CIA* និង *KGB"* ។ លើសពីនេះទៀត សាក្សី ២រូប បានរៀបរាប់អំពីវិធីដែលអ្នកសួរចម្លើយប្រើប្រាស់ គឺមិនឱ្យបរាជ័យដល់ *"អង្គការ"* គឺធ្វើឱ្យបានហ្មត់ចត់ ។

ទោះបីជា លោក **វ៉ាន់ ណាត** បានចៀសផុតពីការធ្វើទារុណកម្មនៅមន្ទីរ ស-២១ ក៏លោក **ប៊ូ ម៉េង** និង លោក **ជុំ ម៉ី** បានរំលឹកឡើងនូវការទទួលរងការវាយតប់ និងឆក់ខ្សែភ្លើង ដែលវិធីសាស្ត្រទាំងពីរនេះអនុវត្តជាប្រចាំនៅមន្ទីរ ស-២១ (តាមសក្ខីកម្មរបស់ **ឌុច**) ។ លើសពីនេះទៀត លោក **ជុំ ម៉ី** បានរៀបរាប់ពីវិធីដកក្រចក ដែលក្រចកមេជើងគាត់ត្រូវបានបាត់បង់ ដោយការធ្វើទារុណកម្មនោះ ។ លោក **វ៉ាន់ ណាត** និងលោក **ជុំ ម៉ី** ត្រូវបានធ្វើទារុណកម្មឱ្យផ្តល់ចម្លើយសារភាពក្លែងក្លាយ ចំណែកលោក **ប៊ូ ម៉េង** ត្រូវបានបង្ខំឱ្យចុះហត្ថលេខាជាមុន លើសេចក្តីព្រាងចម្លើយសារភាព ។

ចំពោះការចូលរួមរបស់**ឌុច**ក្នុងការធ្វើទារុណកម្ម សាក្សីព្រមទាំងដើមបណ្តឹងរដ្ឋប្បវេណី បានផ្តល់សក្ខីកម្មស្រដៀងគ្នាថា **ឌុច** មិនបានធ្វើទារុណកម្មពួកគេដោយផ្ទាល់ទេ និងមិនធ្លាប់ឃើញ **ឌុច** ធ្វើទារុណកម្មអ្នកទោសផ្សេងដែរ ។ លោក **ប៊ូ ម៉េង** គឺជាដើមបណ្តឹងរដ្ឋប្បវេណីតែម្នាក់គត់ដែលលើកឡើងថា បានឃើញ **ឌុច** បញ្ជាឱ្យធ្វើទារុណកម្មអ្នកទោសជនជាតិវៀតណាម ប៉ុន្តែនៅពេល មេធាវីការពារក្តីលោក **ការ សាវុត្ថ** សួរបញ្ជាក់បញ្ហានេះ គាត់ទទួលស្គាល់ថា មិនបានចាំច្បាស់ពីហេតុការណ៍នោះទេ និងមិនបានដឹងថា អ្នកណាជាអ្នកបញ្ជាឱ្យធ្វើការទារុណកម្មដែរ ។

***អ្នកទោសបរទេសនៅមន្ទីរ ស-២១ :*** នៅពេលឆ្លើយសំណួររបស់លោកស្រីចៅក្រម **Sylvia Cartwright** លោក **ប៊ូ ម៉េង** បានរៀបរាប់ថា មានវត្តមានរបស់អ្នកទោសបរទេសម្នាក់នៅបន្ទប់រួមជាមួយគាត់ ។ គាត់បន្ថែមទៀតថា បានឃើញមនុស្សស្បៀកពាក់ឯកសណ្ឋាន ទាហ៊ានវៀតណាម នៅពេលពួកគេមកដល់មន្ទីរ ស-២១ ។

***ការចាប់សមាជិកគ្រួសារ :*** សាក្សីបានបញ្ជាក់ថា ការលើកឡើងរបស់**ឌុច** អំពីនយោបាយចាប់ខ្លួនសមាជិកគ្រួសារទាំងអស់ ប្រសិនបើមានសមាជិកណាម្នាក់ត្រូវចាត់ទុកជាខ្មាំងនោះ ដូចជា លោក **ប៊ូ ម៉េង** ត្រូវចាប់ខ្លួនរួមជាមួយប្រពន្ធ, លោក **ជុំ ម៉ី** ត្រូវចាប់ខ្លួនបន្ទាប់មកប្រពន្ធរបស់គាត់ក៏ត្រូវបានចាប់បញ្ជូនទៅព្រៃសដែរ ។ ចំណែកឯម្តាយលោក **នង ចាន់ផល** ត្រូវបានចាប់ខ្លួនប៉ុន្មានខែបន្ទាប់ពីគេហៅឪពុករបស់គាត់ទៅភ្នំពេញ ។ យោងតាមប្រវត្តិរូបនៅមន្ទីស-២១ គួរឱ្យជឿបានថា ឪពុករបស់លោក **នង ចាន់ផល** ត្រូវបានឃុំខ្លួននៅមន្ទីរ ស-២១ ។

***ការជម្រុញចិត្តផ្តល់សក្ខីកម្ម និងការទន្ទឹងចង់បានពីតុលាការខ្មែរក្រហម :*** សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានកោះហៅមកផ្តល់សក្ខីកម្មនាសប្តាហ៍នេះ បានសម្តែងសេចក្តីសង្ឃឹមយ៉ាងមុតមាំថា សក្ខីកម្មរបស់ពួកគេនឹងជួយសម្រេចបាននូវយុត្តិធម៌ជូនក្រុមគ្រួសារ និងអ្នកបាត់បង់ជីវិតក្នុងរបបខ្មែរក្រហម ។ សាក្សី **វ៉ាន់ ណាត** បានរៀបរាប់យ៉ាងខ្លី និងពីមូលហេតុដែលនាំឱ្យគាត់ចូលរួមក្នុងការជំនុំជម្រះ ដោយបញ្ជាក់ពីក្តីសង្ឃឹមថា សក្ខីកម្មរបស់គាត់នឹងអាចជួយឱ្យក្មេងជំនាន់ក្រោយយល់ដឹងពីជីវិតអ្នក

ដែលត្រូវបានចាប់ខ្លួនដោយគ្មានមូលហេតុ និងកំហុស ។ គាត់បានបន្ថែមថា គាត់កំពុងទន្ទឹងរង់ចាំ *"យុត្តិធម៌សម្រាប់អ្នកស្លាប់.... ខ្ញុំសង្ឃឹមថា យុត្តិធម៌នឹងមានសម្រាប់មនុស្សគ្រប់រូប"* ។ សាក្សីខ្លះបញ្ជាក់ថា ការមកផ្ដល់សក្ខីកម្មនៅមុខ អ.វ.ត.ក នេះ អាចជួយឱ្យស្ងប់ចិត្ត និងរំងាប់អារម្មណ៍ភ័យខ្លាច ដូចលោក **ប៊ូ ម៉េង** បានលើកឡើងថា *"ខ្ញុំត្រេកអរណាស់ព្រោះឥឡូវខ្ញុំហាក់ដូចធូរទ្រូងជាងមុន.... រាល់ការឆ្លើយរបស់ខ្ញុំនៅមុខចៅក្រម មេធាវី និងភាគីផ្សេងទៀត ធ្វើឱ្យខ្ញុំមានអារម្មណ៍ធូរស្រាលជាងមុន"* ។

## ២. បញ្ហាកើតមានក្នុងពេលជំនុំជម្រះ

***ការចូលរួមប្រព្រឹត្តសហឧក្រិដ្ឋកម្មរួម (JCE) :*** នៅថ្ងៃច័ន្ទ អង្គជំនុំជម្រះបានលើកឡើងពីការអនុវត្តន៍ JCE ដោយកត់សម្គាល់ពីការដាក់ឯកសាររបស់សហព្រះរាជអាជ្ញា កាលពីថ្ងៃទី០៩ ខែមិថុនា ២០០៩ ស្នើពីប្រភេទ JCE ទី១ ទី២ និងទី៣ អាចអនុវត្តបាន ។ អង្គជំនុំជម្រះបានបញ្ជាក់ពីបំណងរបស់ខ្លួននឹងសម្រេចពីបញ្ហានេះ នៅពេលចេញសេចក្ដីសម្រេចចុងក្រោយ ប៉ុន្តែភាគីអាចដាក់អំណះអំណាង និងសេចក្ដីសន្និដ្ឋានមុនបាន ។

***ការដេញដោលលើដើមបណ្ដឹងរដ្ឋប្បវេណី :*** ដើមបណ្ដឹងរដ្ឋប្បវេណី ២រូប ត្រូវបានកោះហៅដោយអង្គជំនុំជម្រះ នាសប្ដាហ៍នេះ គឺលោក **ជុំ ម៉ី** និងលោក **ប៊ូ ម៉េង** ។ យោងតាមវិធានផ្ទៃក្នុង វិធាន២៣.៦ ចែងថា *ដើមបណ្ដឹងរដ្ឋប្បវេណីមិនត្រូវបានស្ដាប់ចម្លើយក្នុងនាមជាសាក្សីក្នុងសំណុំរឿងទេ* ។ ទោះបីជាយ៉ាងណា ក្រុមឃ្លាំមើលតុលាការមិនអាចយល់ពីភាពខុសគ្នានូវការដេញដោលដែលអង្គជំនុំជម្រះ និងភាគីចោទសួរដើមបណ្ដឹងរដ្ឋប្បវេណីទាំង ២រូប និងសាក្សីផ្សេងទៀតដែលកោះហៅក្នុងសប្ដាហ៍នេះ ដោយសារបញ្ហានេះ អង្គជំនុំជម្រះបានណែនាំឱ្យមានការបកស្រាយលើវិធាន ២៣.៦(ក) ។

***ភាពអាចទទួលយកបាន និងសេចក្ដីពិតនៃភស្តុតាង :*** មុនពេលសវនាការសួរដេញដោលលើសក្ខីកម្មលោក **នង ចាន់ផល** នៅព្រឹកថ្ងៃព្រហស្បតិ៍នេះ សហព្រះរាជអាជ្ញាអន្តរជាតិលោក **William Smith** បានដាក់សំណើចំនួនពីរ ចំពោះមុខអង្គជំនុំជម្រះ ទី១ សេចក្ដីថ្លែងធ្វើដោយសាក្សីចំពោះមុខមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី១៣ ខែកុម្ភៈ ២០០៩ គួរត្រូវដាក់នៅមុខអង្គជំនុំជម្រះដោយអនុលោមតាមវិធាន ៨៧.៤ និង ទី២ ការបញ្ចាំងផ្ទៃកមួយនៃវីដេអូដែលទទួលបានមកពីប្រទេសវៀតណាម គួរត្រូវបានបង្ហាញចំពោះមុខលោក **នង ចាន់ផល** ព្រោះជាឱកាសល្អក្នុងការបញ្ជាក់ជាមួយសាក្សី នូវភាពពិតនៃរូបភាពវីដេអូ ។

## ៣. ការចូលរួម និងការការពារសាក្សី និងជនរងគ្រោះ

***វត្តមានដើមបណ្ដឹងរដ្ឋប្បវេណី :*** មានដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៧រូប បានចូលរួមសវនាការ នៅថ្ងៃច័ន្ទ និងថ្ងៃអង្គារ ។ នៅថ្ងៃពុធដើមបណ្ដឹងកើនដល់ ៩រូប រាប់បញ្ចូលទាំងសាក្សី **ប៊ូ ម៉េង** ។ នៅថ្ងៃព្រហស្បតិ៍ ចំនួនដើមបណ្ដឹងធ្លាក់នៅតែ ៦រូបប៉ុណ្ណោះ ។

***ការគាំពារជនរងគ្រោះ និងសាក្សី :*** សក្ខីកម្មសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីនាសប្ដាហ៍នេះ បានបង្ហាញនូវកម្រិតទុក្ខសោកផ្សេងៗគ្នា នៅពេលរៀបរាប់ពីភាពឃោរឃៅប្រព្រឹត្តមកលើរូបគេ និងសមាជិកគ្រួសារ នៅមន្ទីរ ស-២១ ។ ទោះបីជាដើមបណ្ដឹង

មានការរំជួលចិត្តជាច្រើនលើកក្នុងពេលផ្តល់សក្ខីកម្ម ក្រុមឃ្លាំមើលតុលាការសង្កេតឃើញថា លោក **ជុំ ម៉ី** និងលោក **នង ចាន់ផល** គឺបង្ហាញនូវភាពទុកព្រួយជាខ្លាំង នៅពេលរៀបរាប់ពីបទពិសោធន៍ឈឺចាប់របស់ខ្លួន ។

***ការស្នើសុំឱ្យបង្ហាញស្លាកស្នាមរបួស :*** ក្នុងការប៉ុនប៉ងបញ្ជាក់ពីស្លាកស្នាមរបួស ដោយសារការធ្វើទារុណកម្មលើលោក **ជុំ ម៉ី** និងលោក **ប៊ូ ម៉េង** ប្រធានអង្គជំនុំជម្រះ **និល ណុន** បានស្នើឱ្យពួកគេបង្ហាញស្លាកស្នាមរបួសទាំងនោះជាសាធារណៈ ។ ជាការឆ្លើយតបចំពោះសំណើនេះ សាក្សីទាំង ២រូប ហាក់ដូចជាចង់បង្ហាញនូវស្លាកស្នាមទាំងនេះ ប៉ុន្តែសំណើរបស់ប្រធានអង្គជំនុំជម្រះទៅលោក **ប៊ូ ម៉េង** មេធាវី **Silke Studzinsky** បានអន្តរាគមន៍ស្នើទៅអង្គជំនុំជម្រះសម្រាក ដើម្បីរៀបចំវិធានការសមស្របចំពោះបញ្ហានេះ ។ នៅពេលត្រលប់ពីសម្រាកវិញ អង្គជំនុំជម្រះបានដកសំណើនោះចេញ ហើយប្រាប់លោក **ប៊ូ ម៉េង** ឱ្យគាត់ថតរូបស្លាកស្នាមរបួសដាក់ជាភស្តុតាងជំនួស ។ ទោះជាយ៉ាងនេះក្តី ក្រុមឃ្លាំមើលតុលាការយល់ថា ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីគួត្រូវទុកជម្រើសក្នុងការសម្រេចបង្ហាញស្នាមរបួសនោះនៅក្រោយការផ្តល់សក្ខីកម្ម ។

## ៤. ការគ្រប់គ្រងសវនាការ

***វត្តមានភាគី :*** នៅថ្ងៃច័ន្ទ និងថ្ងៃពុធ សហព្រះរាជអាជ្ញាលោក **Robert Petit** មានវត្តមាន ។ នៅថ្ងៃអង្គារ និងព្រហស្បតិ៍ លោក **William Smith** តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។ លោក **យ៉េត ចរិយា** តំណាងសហព្រះរាជអាជ្ញាជាតិ នៅថ្ងៃច័ន្ទ លោក **តាន់ សេណារុង** តំណាងនៅថ្ងៃអង្គារ និងថ្ងៃប្រសហ្បតិ៍ ចំណែកលោក **សេង ប៊ុនឃាង** តំណាងនៅថ្ងៃពុធ ។ មេធាវីការពារក្តីអន្តរជាតិលោក **Roux** អវត្តមានពេញមួយសប្តាហ៍ ដែលជំនួសដោយលោកស្រី **Marie-Paule Carnizares** ។

***វត្តមានសាធារណៈជន :*** ផ្នែកកិច្ចការសាធារណៈតុលាការ បានរៀបចំប្រជាពលរដ្ឋ សិស្ស-និស្សិត ចូលរួមនាសប្តាហ៍នេះ ។ នៅព្រឹកថ្ងៃច័ន្ទ ប្រជាពលរដ្ឋប្រហែល ៥០០នាក់ មកពីស្រុកគៀនស្វាយ ខេត្តកណ្តាល មានវត្តមាននៅសាលវិនាការ។ នៅព្រឹកថ្ងៃអង្គារ និស្សិតប្រហែលជា ៤៥០នាក់ មកពីសកលវិទ្យាល័យអាស៊ី-អឺរ៉ុប និងសកលវិទ្យាល័យឯកទេសនៃកម្ពុជា ចំណែកឯនៅពេលរសៀល មានប្រជាពលរដ្ឋ ៤០នាក់ទៀត មកពីខេត្តពោធិសាត់ ឧបត្ថមដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ។ នៅថ្ងៃពុធ ៣១២នាក់ មកពីស្រុកគៀនស្វាយ ខេត្តកណ្តាល និងនិស្សិត ៥០នាក់ទៀត មកពីមហាវិទ្យាល័យបច្ចេកទេសកម្ពុជាចូលរួម ។ នៅថ្ងៃព្រហស្បតិ៍ ប្រជាពលរដ្ឋ ៣០០នាក់ មកពីស្រុកកងមាស ខេត្តកំពង់ចាម ។

***ការគ្រប់គ្រងផ្នែកតុលាការ :*** កិច្ចនីតិវិធីនាសប្តាហ៍នេះ ប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធិភាពខ្ពស់ ។ គួរកត់សម្គាល់ អង្គជំនុំជម្រះបានបើក និងបិទសវនាការគោរពទៅតាមម៉ោងកាលដែលបានកំណត់ ។

អង្គជំនុំជម្រះបានបង្ហាញឱ្យឃើញនូវគោលបំណង ដើម្បីសម្រេចបានប្រសិទ្ធិភាពខ្ពស់ពាក់ព័ន្ធការកំណត់រយៈពេលសួរដេញដោលរបស់ភាគី ដូចជា ការច្រានចោលសំណើរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីចំនួន ពីរលើកក្នុងការស្នើសុំបន្ថែមពេលសួរដេញដោល ។ ម្យ៉ាងទៀត អង្គជំនុំជម្រះបានអនុញ្ញាតតាមសំណើដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ កញ្ញា **ទី ស្រីណា** ក្នុងការបន្ថែមម៉ោងសួរសំណួរសាក្សី **ជុំ ម៉ី** ប៉ុន្តែអង្គជំនុំជម្រះមិនបានបង្ហាញនៅហេតុផលនៃការសម្រេចនោះទេ ដោយគ្រាន់តែកត់សម្គាល់ថា

*"មេធាវីអន្តរជាតិតែងរំលោភរយៈពេលដែលបានកំណត់ក្នុងការសួរដេញដោល"* ។

ឆ្លើយតបនឹងសំណើលោកស្រី **Silke Studzinsky** អង្គជំនុំជម្រះបានផ្តល់ការបញ្ជាក់ពីការអនុវត្តការកំណត់រយៈពេលដែលបានរៀបចំនៅក្នុងកាលវិភាគ ។ ប្រធានអង្គជំនុំជម្រះ **និល ណុន** បានពន្យល់ថា រយៈពេលកំណត់ដល់គូភាគីនីមួយៗ ក្នុងការសួរដេញដោលសាក្សី គឺមិនរាប់បញ្ចូលនូវការជំទាស់ ការសន្និដ្ឋានឆ្លើយឆ្លង និងព្រឹត្តការណ៍ផ្សេងៗទេ ។

***ការគ្រប់គ្រងផ្នែកតុលាការ :*** អង្គជំនុំជម្រះសម្រេចកាត់បន្ថយសាក្សីចេញពីបញ្ជីផ្តល់សក្ខីកម្ម ដើម្បីពន្លឿននីតិវិធី មានចំនួនប្រហែល ១៥រូប ។ អង្គជំនុំជម្រះបានពន្យល់ថា បន្ទាប់ពីការបង្ហាញភស្តុតាងជាមុនដោយភាគី ដែលចង្អុលថា សាក្សីមួយចំនួនហាក់ដូចជា *"ផ្តល់សក្ខីកម្មប្រហាក់ប្រហែលគ្នា"* ប៉ុន្តែសក្ខីកម្មទាំងនោះនឹងពិចារណាជា *"ភស្តុតាង"* ។ គួរកត់សម្គាល់ ភាគីនៅតែពិចារណាលើសាក្សី **KW-24** ដោយអង្គជំនុំជម្រះបានអញ្ជើញសហព្រះរាជអាជ្ញាដាក់នូវសេចក្តីផ្លានរបស់ខ្លួន ។ នៅថ្ងៃអង្គារ អង្គជំនុំជម្រះ បានប្រកាសនូវកាលវិភាគថ្មីសម្រាប់សវនាការលើការផ្តល់សក្ខីកម្មសាក្សី និងសម្រេចដកសាក្សី **KW-24** ចេញពីបញ្ជីឈ្មោះសាក្សី ។

***សំណួរច្រំដែល :*** នៅថ្ងៃច័ន្ទ ក្រុមអ្នកឃ្លាំមើលតុលាការបានសង្កេតឃើញថា លោកចៅក្រម **ធូ មណី** បានតាំងសំណួរដែលសាក្សីបានឆ្លើយរួចហើយ ប៉ុន្តែប្រធានអង្គជំនុំជម្រះ **និល ណុន** មិនបានប៉ុនប៉ងកាត់សំណួររបស់លោកចៅក្រមទេ ទោះបីជាអង្គជំនុំជម្រះ តែងតែដាស់តឿនជាញឹកញាប់ដល់ភាគីពីការចៀសវាងសួរសំណួរច្រំដែល ។

***វិន័យនៅក្នុងសវនាការ :*** ការនឹកឃើញឡើងវិញនូវការឈឺចាប់បានបង្កឱ្យសាក្សីមានការរំជួលចិត្តយ៉ាងខ្លាំង ដែលធ្វើឱ្យគាត់ប្រើនូវវាចារមិនសមរម្យនៅសាលសវនាការ ។ *<u>ឧទា :</u>* សាក្សី **ជុំ ម៉ី** បាននិយាយថា *"**ឌុច** នឹងមិនមានជីវិតឃើញពន្លឺថ្ងៃទេ"* ប្រសិនបើ **ឌុច** បានធ្វើទារុណកម្មដោយផ្ទាល់លើគាត់ ។ ប្រធានអង្គជំនុំជម្រះ **និល ណុន** បានរំលឹកដល់សាក្សីឱ្យទប់ស្មារតីរបស់គាត់កុំឱ្យមានការ *"ការជេរប្រមាថជនជាប់ចោទ"* ។

***កង្វល់ពាក់ព័ន្ធនឹងការបកប្រែ :*** ការបកប្រែភាសាសប្តាហ៍នេះ គឺល្អប្រសើរតភ្ជាប់គ្នាជាលំដាប់ ។ ជាងនេះទៀត អង្គជំនុំជម្រះបានរៀបចំម៉ៃក្រូហ្វូនបំពងសម្លេងដោយស្វ័យប្រវត្តិដល់សាក្សី បន្ទាប់ពីការបកប្រែជួបបញ្ហា ដោយបកប្រែមិនបានពេញលេញព្រោះសាក្សីឆ្លើយសំណួរតែមិនបើកប្រដាប់បំពងសំលេង ។ ក្រុមអ្នកឃ្លាំមើលតុលាការបានឱ្យដឹងថា ការរៀបចំថ្មីនេះ គឺជាកិច្ចខំប្រឹងប្រែងគួរឱ្យកោតសរសើរ ដើម្បីធានាការបកប្រែឱ្យបានត្រឹមត្រូវ ។ ទោះបីយ៉ាងណា ក្រុមអ្នកឃ្លាំមើលតុលាការខ្មែរបានកត់សម្គាល់ ថាគុណភាពនៃការបកប្រែជាភាសាខ្មែរពិបាកយល់ កាលពីព្រឹកថ្ងៃព្រហស្បត្តិ៍ ។

***បញ្ហាបច្ចេកទេស :*** ជាទូទៅ កិច្ចសវនាការនាសប្តាហ៍នេះប្រព្រឹត្តទៅដោយរលូន គ្មានបញ្ហាបច្ចេកទេសសំខាន់នោះទេ ជួបតែករណីតូចមួយនៅថ្ងៃច័ន្ទ នៅពេលអង្គជំនុំជម្រះប៉ុនប៉ងបង្ហាញរូបភាពលើអេក្រង់ជាសាធារណៈ ប៉ុន្តែមានការរអាក់រអួល ដែលជាហេតុធ្វើឱ្យប្រធានអង្គជំនុំជម្រះសុំជំនួយពីសហព្រះរាជអាជ្ញាជួយសម្រួលបញ្ហានេះ ។

| ថ្ងៃកាលបរិច្ឆេទ | ចាប់ផ្តើម | សម្រាក់ព្រឹក | សម្រាកថ្ងៃត្រង់ | សម្រាក់រសៀល | បញ្ឈប់ | ចំនួនម៉ោងសរុប |
|---|---|---|---|---|---|---|
| ចន្ទ័ ២៩,០៦,០៩ | ០៩.០៥ | ១០.៤០-១១.០០ | ១២.០៥-១៣.៣០ | ១៤.៤៥-១៥.០៥ | ១៥.៤០ | ៤ម៉ ៣០នាទី |
| អង្គារ ៣០,០៦,០៩ | ០៩.០០ | ១០.៣០-១០.៥០ | ១១.៤៥-១៣.៣៨ | ១៤.៥០-១៥.១៥ | ១៥.៤៥ | ៤ម៉ ០៧ នាទី |
| ពុធ ០១,០៧,០៩ | ០៩.០៥ | ១០.៣០-១០.៥០ | ១២.០០-១៣.៣០ | ១៤.៤០-១៥.០០ | ១៦.១០ | ៥ម៉ ០៥នាទី |
| ព្រហស្បត្តិ៍០២,០៧,០៩ | ០៩.០០ | ០៩.៤០ – ១០.២៥<br>១១.២០ –១១.៣០ | ១២.០០-១៣.៣០ | ១៤.៥០-១៥.១០ | ១៤.០០ | ៤ម៉ ២០នាទី |

**ចំនួនម៉ោងសរុបជាមធ្យម ៤ម៉ ៣១នាទី**

**ចំនួនម៉ោងសរុបសប្តាហ៍នេះ ១៨ម៉ ៤នាទី**

**ចំនួនម៉ោងសរុប ថ្ងៃ សប្តាហ៍ សវនាការ ១៩៦ម៉ ៣៤នាទី ៣៧ថ្ងៃ ១០សប្តាហ៍**

---

**អំពីកម្មវិធីអ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម** (“កម្មវិធី”) : ជាកម្មវិធីរបស់អង្គការ the Asian International Justice Initiative (AIJI) ដែលជាកិច្ចសហការណ៍រវាង U.C. Berkeley War Crimes Studies Center និង East-West Center ។

កម្មវិធីនេះចេញរបាយការណ៏ប្រចាំសប្តាហ៏ អំពីកិច្ចដំណើរការនីតិវិធីសវនាការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ឬតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ បច្ចុប្បន្ន កម្មវិធីនេះកំពុងតែឃ្លាំមើលដំណើរការនៃការកាត់ទោសលើសំណុំរឿង **កាំង ហ្គិចអ៊ាវ** ហៅ **ឌុច** ដែលជារឿងក្តីដំបូងឈានដល់ដំណាក់កាលជំនុំជម្រះ ។

របាយការណ៏ប្រចាំសប្តាហ៏នេះ ត្រូវបានរៀបចំដោយក្រុមឃ្លាំមើលតុលាការ ដែលដឹកនាំដោយលោកស្រី **Michelle Staggs** ជានាយិការងនៃអង្គការ AIJI ដែលមានសមាសភាពដូចខាងក្រោម :

**ក្រុមទី១**
- លោកស្រី **ជូ វិនាថ** : ប្រធានកម្មវិធីសង្កេតការណ៏តុលាការនៃ CSD
- លោក **ង៉ែត សុវណ្ណនិត** : បុគ្គលិកអង្គការ KID
- កញ្ញា **Yvette Anthony** : សិង្ហបុរី
- លោក **Florian Hansen** : អាល្លឺម៉ង់
- កញ្ញា **Caroline Ehlert Zurich** : ស្វីស
- កញ្ញា **Deepika Sharma** : សហរដ្ឋអាមេរិក

**ក្រុមទី២**
- កញ្ញា **សេក សុវណ្ណា** : មេធាវី អង្គការ CLEC
- លោក **ភ័ក្រ្ត សាវ៉ន** : បុគ្គលិកអង្គការ UNOHCHR
- កញ្ញា **Aviva Nababan** : ឥណ្ឌូនេស៊ី
- កញ្ញា **Romana Weber** : ស្វីស
- កញ្ញា **Binxin Zhang** : ចិន
- លោក **Jaspreet Dosanjh** : សហរដ្ឋអាមេរិក

កម្មវិធីនេះ បានសហការជាមួយមជ្ឈមណ្ឌលអភិវឌ្ឍន៏សង្គម (CSD) និង (KID) ដើម្បីផ្សព្វផ្សាយរបាយការណ៏នេះ ។ លោក-អ្នកអាចរកបាននូវរបាយការណ៏នេះជាភាសាខ្មែរ និងអង់គ្លេស នៅក្នុង www.csdcambodia.org ; www.kidcambodia.org និង http://Socrates.berkeley.edu/-warcrime/_ ។